# ការធានារ៉ាប់រងគ្រប់ហានិភ័យលើទ្រព្យសម្បត្តិ

សូមអានកិច្ចសន្យានេះដោយប្រុងប្រយ័ត្ន និងធ្វើការកត់សំគាល់ ខចែងរបស់វា ។
ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រម (ដោយផ្អែកលើ ខចែង និងលក្ខខណ្ឌ និងករណីលើកលែងដែលមាននៅក្នុងកិច្ចសន្យានេះ ឬបដិ្ឋលេខបន្ថែម និងត្រូវបានចាត់ទុកថាជាលក្ខខណ្ឌជាមុន ចំពោះសិទ្ធិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ដើម្បីទទួលបានសំណងមកវិញ) ថា បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងដំបូង

**<u>ផ្នែកទី១ - ការខូចខាតចំពោះទ្រព្យសម្បត្តិ</u>**

ប្រសិនបើមានទ្រព្យស្បត្តិណាមួយ ដែលត្រូវបានធានារ៉ាប់រងស្ថិតនៅក្នុងបរិវេណ នៅក្នុងតំបន់ភូមិសាស្ត្រដែលបានបង្ហាញនៅក្នុងតារាងឧបសម្ព័ន្ធ ត្រូវបានបាត់បង់ បំផ្លាញ ឬខូចខាតជាយថាហេតុ ជារូបវន្ត ជាជាងដោយមូលហេតុដែលត្រូវបានលើកលែង (តទៅត្រូវបានប្រើពាក្យថា ការខូចខាត) ហើយដែលបានកើតឡើងក្នុងអំឡុងពេលធានារ៉ាប់រងណាមួយ ឬក្នុងអំឡុងពេលបន្តបន្ទាប់គ្នាណាមួយ ដោយក្នុងករណីបុគ្គលដែលបានធានារ៉ាប់រង បានបង់បុព្វលាភធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងបានទទួលយកនូវបុព្វលាភនោះ ដែលតម្រូវសម្រាប់ការបន្តនូវកិច្ចសន្យានេះ

ក្រុមហ៊ុនធានារ៉ាប់រង នឹងបង់សំណងជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវតម្លៃជាក់ស្តែងនៃទ្រព្យសម្បត្តិ នៅពេលដែលកើតមានការខូចខាត ឬតាមជម្រើសរបស់ខ្លួនតាមរយៈការធ្វើឲ្យដូចដើមវិញ ឬជំនួសទ្រព្យសម្បត្តិ ឬផ្នែកណាមួយនៃទ្រព្យសម្បត្តិដែលបានខូចខាត

**<u>ផ្នែកទី២ - ការខាតបង់ប្រាក់ចំណូល</u>**

ប្រសិនបើនៅពេលណាមួយក្នុងអំឡុងពេលនៃការធានារ៉ាប់រង អាជីវកម្មដែលធ្វើឡើងដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងនៅក្នុងបរិវេណដូចដែលមានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ ត្រូវបានរំខាន ឬជ្រៀតជ្រែក ដែលជាលទ្ធផលបណ្តាលឲ្យមានសំណងលើការខូចខាតទ្រព្យសម្បត្តិនៅក្នុងផ្នែកទី ១ នោះក្រុមហ៊ុនធានារ៉ាប់រងនឹងធ្វើសំណងជូនបុគ្គលដែលត្រូវបានធានារងនូវចំនួនទឹកប្រាក់ចំណូលដែលខាតបង់ដោយសារការរំខាន ឬការជ្រៀតជ្រែក យោងតាមលក្ខខណ្ឌដែលមានចែង និងបញ្ជាក់ជូនក្នុងផ្នែកទី ២ នេះ ។

ដោយហេតុថា នៅពេលដែលកើតមានការខូចខាតទ្រព្យសម្បត្តិ ត្រូវមានការធានារ៉ាប់រងជាធរមាន ដែលធានាលើទ្រព្យសម្បត្តិដែលមាននៅក្នុងបរិវេណចំពោះការខូចខាតនេះ និង

(i) ការបង់ប្រាក់សំណងចំពោះការខូចខាតលើទ្រព្យសម្បត្តិត្រូវបានធ្វើឡើង ឬការទទួលខុសត្រូវ ត្រូវបានទទួលស្គាល់ ឬ

(ii) ការបង់ប្រាក់សំណងលើទ្រព្យសម្បត្តិដែលត្រូវបានធ្វើឡើង ហើយការទទួលខុសត្រូវបានទទួលស្គាល់ប៉ុន្តែសម្រាប់ការអនុវត្តនូវលក្ខខណ្ឌក្នុងការធានារ៉ាប់រងនេះ គឺមិនរួមបញ្ចូលនូវទំនួលខុសត្រូវចំពោះការខាតបង់ក្រោមចំនួនទឹកប្រាក់ដែលបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធឡើយ ។

ដោយហេតុថា ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង យោងតាមផ្នែកនីមួយៗ ក្នុងអំឡុងពេលធានារ៉ាប់រងណាមួយនឹងមិនត្រូវលើសពី

(i) ចំនួនទឹកប្រាក់ដែលបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ សម្រាប់ទ្រព្យសម្បត្តិនីមួយៗ ឬចំនួនទឹកប្រាក់សរុបដែលត្រូវបានធានារ៉ាប់រង

(ii) ដែនកំណត់នៃការទទួលខុសត្រូវណាមួយ ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ ឬចំនួនទឹកប្រាក់សរុបផ្សេងទៀតឬជាច្រើនទៀតដែលអាចត្រូវបានជំនួសដោយអនុស្សរណៈឬដែលភ្ជាប់មកជាមួយ ព្រមទាំងចុះហត្ថលេខាដោយ ឬក្នុងនាមក្រុមហ៊ុនធានារ៉ាប់រង។

**ករណីលើកលែង (ដែលអនុវត្តចំពោះផ្នែកទី ១ និងទី ២)**

**ក - ខចែងស្តីពីករណីលើកលែង**

កិច្ចសន្យានេះធានាលើ

១- ការខូចខាតទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងបណ្តាលមកពី

(ក) (i) សម្ភារ ឬស្នាដៃកែច្នៃដែលមានកំហុសឆ្គង ឬភាពខ្វះចន្លោះដែលមិនបញ្ចេញឲ្យឃើញ ការខូចខាតជាបន្តបន្ទាប់ ការបង្ខូចទ្រង់ទ្រាយ ដំណើរខុសភាពដើម ឬសំណឹករេចរឹល

(ii) ការរអាក់ខាននៃដំណើរការផ្គត់ផ្គង់ទឹក ហ្គាស អគ្គីសនី ឬប្រព័ន្ធប្រភពថាមពល ឬការមិនដំណើរការប្រព័ន្ធបញ្ចេញចោលកាកសំណល់ទៅ និងចេញពីបរិវេណអគារ

(iii) ការផ្លាស់ប្តូរទិស ឬស្រទាប់នៃគ្រោងអគារ ការពង្រួញ ឬពង្រីកគ្រឹះនៃអគារ ជញ្ជាំង ផ្ទៃ ឬពិដាននៃអគារ ប្រសិនណាការខូចខាតដោយមូលហេតុ ដែលមិនមានក្នុងករណីលើកលែងក្នុងលទ្ធផលនៃកិច្ចសន្យានោះក្រុមហ៊ុនធានារ៉ាប់រងត្រូវទទួលខុសត្រូវសម្រាប់តែការខូចខាតដែលមានការធានាតែប៉ុណ្ណោះ

(ខ) (i) ការដួលរលំ ឬបាក់បែកអគារ

(ii) ច្រេះ ស្នឹម ឬការផ្លាស់ប្តូរសីតុណ្ហភាព សំណើម កម្តៅ ភាពសើម ឬភាពស្ងួត រលួយ រុក្ខជាតិប្រភេទផ្សិត ការរួញ រំហួត ការបាត់បង់ទម្ងន់ ការបំពុល ការចំលងរោគ ការផ្លាស់ប្តូរពណ៌ រសជាតិ សណ្ឋាន ឬបញ្ចប់សកម្មភាពពន្លឺ សត្វល្អិតចង្រៃ សត្វល្អិត ស្នាម ឬកោស ឬគុណវិបត្តិផ្សេងៗលើកលែងតែការបាត់បង់ទាំងនោះ បណ្តាលឲ្យមានការខូចខាតដោយផ្ទាល់ដល់ទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រងឬ បរិវេណដែលមានទ្រព្យសម្បត្តិបែបនេះ ដោយសារមូលហេតុដែលមិនស្ថិតនៅក្នុងករណីលើកលែង

(គ) (i) អំពើចោរកម្ម លើកលែងតែបង្កឡើងដោយហិង្សា ឬការគំរាមគំហែងចំពោះបុគ្គលណាម្នាក់ ឬដោយបង្ខំ ឬការចូល ឬចេញពីបរិវេណអគារដោយការប្រើកម្លាំង ឬហិង្សា

(ii) ឧបករណ៍ក្លែងបន្លំ ឬការប៉ុនប៉ងមិនត្រឹមត្រូវដែលអនុវត្តដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬបុគ្គលណាមួយផ្សេងទៀត ដែលមើលការខុសត្រូវលើទ្រព្យសម្បត្តិរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

(iii) សកម្មភាពមិនត្រឹមត្រូវ ឬសកម្មភាពមិនស្មោះត្រង់ណាមួយរបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬនិយោជិតណាម្នាក់របស់ បុគ្គលដែលត្រូវបានធានារ៉ាប់រង ។

(iv) ការលិចបាត់ ដែលមិនអាចពន្យល់បាន ឬកង្វះខាតសន្និធិ ការបំពេញខុស ឬការដាក់ច្រលំនូវពត៌មាន កង្វះខាតក្នុងការផ្គត់ផ្គង់ ឬការបញ្ជូនសម្ភារៈ ឬកង្វះខាតដោយបញ្ជាកត់ត្រា ឬប្រព័ន្ធគណនី

(v) ការបាក់បែក ច្រេះ ការដួលរលំ ឬការឡើងកម្តៅនៃប្រព័ន្ធចំហាយទឹក ប្រព័ន្ធផ្លាស់ប្តូរកម្តៅ ប្រព័ន្ធរថភ្លើងក្រោមដី កប៉ាល់ ឬការលេចធ្លុះធ្លាយនៃបំពង់ ឬកន្លែងតភ្ជាប់នៃប្រព័ន្ធចំហាយទឹក ឬការមិនដំណើរការនៃកន្លែងតភ្ជាប់ផ្សេងៗទៀតនៃប្រព័ន្ធ ចំហាយទឹក

(vi) ការខូចខាតប្រព័ន្ធអគ្គីសនី ឬប្រព័ន្ធមេកានិក ឬការរុះរើម៉ាស៊ីន ឬឧបករណ៍ រួមមានការតម្លើងគ្រឿងអេឡិចត្រូនិច កុំព្យូទ័រ និងឧបករណ៍ដំណើរការទិន្នន័យ

(vii) ការខូចខាតចំពោះប្រព័ន្ធចំហាយទឹក ប្រព័ន្ធផ្លាស់ប្តូរកម្តៅ ទួរប៊ីន ឬបំពង់ម៉ាស៊ីនផ្សេងទៀត ឬឧបករណ៍ដែលប្រើប្រាស់ សម្ពាធ ឬឧបករណ៍ពាក់ព័ន្ធផ្សេងៗទៀត ដែលការខូចខាតទាំងនោះ បណ្តាលមកពីការផ្ទុះ ឬការផ្ទុះធ្លាយ

(viii) ការបែកធ្លាយ ការហៀរចេញ ការចេញ ឬការលេចទឹកពីធុងស្តុកទឹក ពីឧបករណ៍ដាក់ទឹកផ្សេងៗទៀត ឬពីបំពង់ទឹកនៅពេល ដែលបរិវេណអគារមិនត្រូវបានប្រើប្រាស់លើសពីសាមសិប (៣០) ថ្ងៃលើកលែងតែ

(i) ការខូចខាតដោយសារមូលហេតុ ដែលមិនមានក្នុងករណីលើកលែងក្នុងកិច្ចសន្យា ហើយក្រុមហ៊ុនធានារ៉ាប់រង ត្រូវទទួល ខុសត្រូវសម្រាប់ករណីខូចខាតណាដែលត្រូវបានធានារ៉ាប់រងតែប៉ុណ្ណោះ នឹង/ឬ

(ii) ការបាត់បង់ទាំងនោះបណ្តាលមកពីការខូចខាតដោយផ្ទាល់ ចំពោះទ្រព្យសម្បត្តិដែលត្រូវបានធានារ៉ាប់រង ឬចំពោះបរិវេណ អគារ ដោយសារមូលហេតុដែលមិនត្រូវបានលើកលែងក្នុងកិច្ចសន្យា

(ឃ) (i) ចម្រោះឆ្នេរសមុទ្រ ឬទន្លេ

(ii) ព្យុះភ្លៀង ខ្យល់ព្យុះ ទឹកភ្លៀង និងទឹកដែលធ្វើឲ្យទទឹកលើទ្រព្យសម្បត្តិនៅក្នុងទីចំហរ (ជាជាងទ្រព្យសម្បត្តិដែលត្រូវបានរចនាឡើងអោយមានភាពធន់ និងដំណើរការនៅទីចំហរ)

(iii) ដំណើរការបង្កឲ្យក្លាយទៅជាអង្គធាតុរឹង ឬការធ្វេសប្រហែសបណ្តាលឲ្យមានការរលាយ ឬការលេចចេញនូវឧស្ម័ន លើកលែងតែក្នុងករណីអគ្គិភ័យ នោះក្រុមហ៊ុនធានារ៉ាប់រងនឹងទទួលខុសត្រូវចំពោះការខូចខាតទាំងនោះ ។

(iv) កំហុសឆ្គងផ្នែកកម្មវិធី ការចោះប្រហោង ធ្វើស្លាកសញ្ញា ឬការធ្វេសប្រហែស ការលុបពតិមាន ឬការបោះបង់ចោលទិន្នន័យ សារពតិមាន និងការបាត់បង់ពតិមានដោយផ្នែកម៉ាញេទិច

២. ការខូចខាតដែលបណ្តាលមកពី ឬកើតឡើងពី

(ក) ទង្វើដោយចេតនាណាមួយ ឬការធ្វេសប្រហែសដោយចេតនារបស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ឬបុគ្គលផ្សេងទៀតក្នុងនាមបុគ្គលដែលត្រូវធានារ៉ាប់រង

(ខ) ការបញ្ឈប់ការងារ

(គ) ការពន្យារពេល ឬការបាត់បង់ទីផ្សារ

(ឃ) ការខាតបង់ផ្នែកហិរញ្ញវត្ថុតាមគ្រប់រូបភាព លើកលែងតែការខាតបង់ទាំងនោះ ត្រូវបានធានារ៉ាប់រងក្នុងផ្នែកទី ២

៣. ការខូចខាតដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលដោយ ឬតាមរយៈ ឬជាលទ្ធផលបណ្តោលមកពីហេតុការណ៍ណាមួយដូចខាងក្រោមនេះ :

(ក) សង្គ្រាម ការឈ្លានពាន សកម្មភាពរបស់សត្រូវបរទេស ការវាយប្រហារ ឬប្រតិបត្តិសឹក (ទោះបីមានការប្រកាសសង្គ្រាមក្តី ឬមិនមានក្តី) ឬសង្គ្រាមស៊ីវិល

(ខ) សង្កុបកម្ម ការរំជើបរំជួលសង្គម ការបះបោរដោយយោធា ឬប្រជាពលរដ្ឋ ការរើបំរះ អំពើឧទ្ទាមបដិវត្តន៍ ការដណ្តើមអំណាចដោយយោធា ឬខុសច្បាប់

(គ) សកម្មភាពភេរវកម្ម

សម្រាប់គោលបំណងនេះ សកម្មភាពភេរវកម្មមានន័យថាសកម្មភាពរួមបញ្ចូលទាំងតែមិនកំណត់លើការប្រើប្រាស់កម្លាំង ឬហិង្សា និង/ឬ ការគំរាមកំហែងរបស់បុគ្គល ឬក្រុមបុគ្គលណាមួយ ទោះជាធ្វើតែម្នាក់ឯង ឬតាងនាមឲ្យ ឬទាក់ទងនិងអង្គការ ឬរដ្ឋាភិបាលណាមួយក៏ដោយដែលពុះពារដើម្បីគោលបំណងនយោបាយ សាសនា មនោគមវិជ្ជា ឬគោលបំណងស្រដៀងគ្នានេះ រួមទាំងការប៉ុនប៉ងជះឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬដើម្បីធ្វើឲ្យសាធារណៈជន ឬផ្នែកណាមួយនៃសាធារណជនស្ថិតក្នុងការភ័យក្លាច

(ឃ) (i) ការដកហូតទ្រព្យសម្បត្តិបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ដោយសារការរឹបអូស ការផ្ទេរជាកម្មសិទ្ធិ

រដ្ឋ ឬសម្រាប់គោលបំណងយោធា ឬរឹបអូសទ្រព្យសាធារណៈជាទ្រព្យសម្បត្តិរដ្ឋដោយអាជ្ញាធរដែលបង្កើតឡើងដោយស្របច្បាប់

(ii) ការដកហូតទ្រព្យសម្បត្តិបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍នូវអគារណាមួយ ដោយសារតែការប្រើប្រាស់អគារទាំងនោះដោយមិនស្របច្បាប់ដោយបុគ្គលណាម្នាក់

ដោយហេតុថា ក្រុមហ៊ុនធានារ៉ាប់រងមិនបានផ្តល់ការទទួលខុសត្រូវណាមួយ ដល់បុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងករណីមានការខូចខាតទ្រព្យសម្បត្តិ ដែលត្រូវបានធានារ៉ាប់រងដែលកើតឡើងមុនពេលការផ្ទេរជាកម្មសិទ្ធិរដ្ឋ ឬក្នុងអំឡុងពេលការផ្ទេរជាកម្មសិទ្ធិរដ្ឋបណ្តោះអាសន្ន ដែលត្រូវបានធានាដោយកិច្ចសន្យានេះ ។

(ង) ការបំផ្លាញទ្រព្យសម្បត្តិដោយបទបញ្ជារបស់អាជ្ញាធរសាធារណៈណាមួយ

ក្នុងសកម្មភាពបណ្តឹងណាមួយ ឬដំណើរការផ្លូវច្បាប់ដ៏ទៃទៀត ដែលក្រុមហ៊ុនធានារ៉ាប់រងទទួលស្គាល់ថាដោយមូលហេតុនៃលក្ខខណ្ឌ ដែលមាននៅក្នុងករណីលើកលែង ក៣ (ក) (ខ) និង (គ) ខាងលើ នោះការបាត់បង់ការបំផ្លាញ ឬការខូចខាតមិនត្រូវបានធ្វើសំណងតាមកិច្ចសន្យានេះ ហើយបន្ទុកក្នុងការបង្ហាញថា ការបាត់បង់ការបង្ហាញ ឬការខូចខាតទាំងនោះត្រូវបានធ្វើសំណងត្រូវធ្លាក់លើបុគ្គល ដែលត្រូវបានធានារ៉ាប់រង

៤. ការខូចខាតដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពី ឬជាប់ពាក់ព័ន្ធនឹង ឬចូលរួមចំណែកបង្កឡើងដោយ

(ក) សព្វាវុធនុយក្លេអ៊ែរ

(ខ) វិទ្យុសកម្មអ៊ីយ៉ុង ឬការបំពុលដោយសកម្មភាពវិទ្យុសកម្មដែលភាយចេញពីឥន្ធនៈនុយក្លេអ៊ែរ ឬពីកាកសំណល់នុយក្លេអ៊ែរ ពីចំហេះឥន្ធនៈនុយក្លេអ៊ែរ ។ សម្រាប់គោលបំណងនៃលក្ខខណ្ឌ ក៤ (ខ) នេះ មានតែចំហេះទេដែលត្រូវរាប់បញ្ចូលនូវដំណើរនៃការបំបែកអាតូមនុយក្លេអ៊ែរដោយឯកឯង ។

## ខ- ទ្រព្យសម្បត្តិដែលមិនត្រូវបានធានារ៉ាប់រង

កិច្ចសន្យានេះមិនធានារ៉ាប់រងលើៈ

១. (ក) ប្រាក់កាស មូលប្បទានប័ត្រ ដុំមាស ឬប្រាក់ ឯកសារធានាការបង់ប្រាក់ និងមូលប័ត្រគ្រប់ប្រភេទ វត្ថុបុរាណមានតម្លៃ ឬការងារសិល្បៈ (ក្រៅអំពីគំនូរ គំនូរលាបពណ៌ និងវត្ថុចម្លាក់នីមួយៗ មិនត្រូវលើសពី ២៥០ដុល្លារ អាមេរិក) សម្លៀកបំពាក់ផលិតពីស្បែកសត្វ គ្រឿងអលង្ការ នាឡិកា គុជខ្យង ត្បូងថ្មៃ ឬមិនទាន់ថ្មៃ មាស ពេជ្រ ប្លាកទីន ឬលោហធាតុ និង លោហៈមានតម្លៃផ្សេងទៀត

(ខ) សៀវភៅសរសេរដោយដៃ គម្រោង គំនូរ ឬប្លង់ ប៉ាន់គំរូ ម៉ូដែល ឬពុម្ព សៀវភៅអាជីវកម្ម ឬប្រព័ន្ធកំណត់ត្រាពតិមានតាមកុំព្យូទ័រ ដែលមានតម្លៃចំពោះបុគ្គលដែលត្រូវបានធានារ៉ាប់រង

(គ) ទ្រព្យសម្បត្តិត្រូវបានលក់ ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងក្នុងលក្ខខណ្ឌលក់ ទំនុកចិត្តកិច្ចព្រមព្រៀង ការបង់ប្រាក់រំលោះ គម្រោង ឬគម្រោងបង់ប្រាក់ ឬបន្ទាប់ពីទ្រព្យសម្បត្តិនោះត្រូវបានផ្ទេរទៅឲ្យអតិថិជនដទៃទៀត

(ឃ) យានយន្តដែលអនុញ្ញាតឲ្យធ្វើចរាចរលើដងផ្លូវ (ដោយរួមបញ្ចូលទាំងគ្រឿងបន្សំផ្សេងៗទៀត) យានដែលអាចស្នាក់នៅ និងបន្លាស់ទីបានដោយការសណ្តោង ផ្លូវរថភ្លើង រថភ្លើង ឬសន្និធិដែលអាចបន្លាស់ទីបាន នាវា យន្តហោះ យានអវកាស ឬយានយន្តស្រដៀងនេះ

(ង) ទ្រព្យសម្បត្តិដែលកំពុងត្រូវបានដឹកជញ្ជូន នៅខាងក្រៅបរិវេណដែលមានបញ្ជាក់នៅក្នុងតារាងឧបសម្ព័ន្ធ

(ច) ទ្រព្យសម្បត្តិ ឬរចនាសម្ព័ន្ធអគារដែលត្រូវបានកម្ទេចចោល សាងសង់ ឬតម្លើង និងសម្ភារ ឬបរិក្ខារដែលជាប់ទាក់ទង

(ឆ) ដី (រួមបញ្ចូល ស្រទាប់ដីខាងលើ ដីចាក់បំពេញ ប្រព័ន្ធលូ ឬលូបង្ហូរទឹកក្រោមដី) ផ្លូវចូលទៅផ្ទះ ចិញ្ចើមផ្លូវ ថ្នល់ ផ្លូវ ផ្លូវយន្តហោះ ផ្លូវរថភ្លើង ផ្លូវរថភ្លើងក្រោមដី ប្រព័ន្ធបញ្ជូនកម្តៅ ដងក្តោង ប្រឡាយបង្ហូរទឹក ប្រព័ន្ធលូបង្ហូរទឹកក្រោមដី ប្រព័ន្ធ អាងស្តុកទឹក និងសម្ភារដែលពាក់ព័ន្ធ កន្លែងស្តុកទឹកបម្រុង ព្រែកជីក ផៃ បំពង់បូមប្រេងពីក្រោមដី ឬពីបាតសមុទ្រ អណ្តូង បំពង់បញ្ជូន ប្រេង ផ្លូវរូងក្នុងដី ស្ពាន ផែចំណត ផែលយទៅក្នុងទឹក ទំនប់ទឹក ការជីកដី កំពង់ទូក ទ្រព្យសម្បត្តិរ៉ែដែលស្ថិតនៅក្រោមដី និងក្រោមផ្ទៃ សមុទ្រ

(ជ) សត្វពាហនៈ សត្វចិញ្ចឹម ការដាំដំណាំ ដើមឈើមិនទាន់កាប់ រុក្ខជាតិ ទីធ្លាមានដំណាំស្មៅ ដើមឈើ និងចុល្លព្រឹក្សសម្រាប់លម្អ

(ឈ) ទ្រព្យសម្បត្តិដែលខូចខាតដោយសារការអនុវត្តដំណើរការណាមួយ

(ញ) ការដំឡើង ការរុះរើ ឬការប្តូរទីតាំងរបស់គ្រឿងចក្រ (រួមមានការដោះ និងការដំឡើងឡើងវិញ) ប្រសិនបើមានទំនាក់ទំនងដោយផ្ទាល់ជាមួយនិងប្រតិបត្តិការទាំងនោះ

(ដ) ទ្រព្យសម្បត្តិដែលកំពុងស្ថិតក្នុងការកែប្រែ ការជួសជុល ការធ្វើសាកល្បង ការដំឡើង ឬការផ្តល់សេវាកម្ម រួមមានសម្ភារៈ និងបរិក្ខារសម្រាប់សកម្មភាពទាំងនោះប្រសិនបើអាចធ្វើអោយមានដំណើរការបានសម្រាប់ការងារដែលកំពុងធ្វើ ប្រសិនបើមិនមានការខូចខាតដោយមូលហេតុណាមួយ ឬបើមិនដូច្នោះទេ មិនរួមបញ្ចូលលទ្ធផល និងបន្ទាប់មកធានាការីនឹងអាចជឿជាក់លើលទ្ធផលនៃការបាត់បង់

(ឋ) ទ្រព្យសម្បត្តិកំពុងត្រូវបានផលិត ។ ប្រសិនបើមានការបាត់បង់ ការបំផ្លិចបំផ្លាញ ឬការខូចខាត នៅពេលកំពុងប្រើប្រាស់ទ្រព្យសម្បត្តិនោះ ឬដោយសារការប្រើប្រាស់នោះ បើមិនដូច្នោះទេ បើការខូចខាតកើតឡើងដោយសារមូលហេតុណាមួយ ដោយមិនគិតពី មូលហេតុបន្ទាប់ពីការប្រើប្រាស់ ហើយក្រុមហ៊ុនធានារ៉ាប់រង នឹងធ្វើសំណងចំពោះការបាត់បង់ដែលកើតមានឡើងបន្ទាប់ពីនោះប៉ុណ្ណោះ ។

(ឌ) ធានារ៉ាប់រងចំពោះទ្រព្យសម្បត្តិជាក់លាក់

២- ការខូចខាតទ្រព្យសម្បត្តិជាក់ស្តែងណាមួយត្រូវបានធានាដោយ ឬនឹង ប៉ុន្តែសម្រាប់ពេលកិច្ចសន្យានេះមានសុពលភាព អាចត្រូវបានធានា ដោយកិច្ចសន្យាធានាលើការដឹកជញ្ជូនតាមសមុទ្រ ឬកិច្ចសន្យាផ្សេងទៀត
លើកលែងតែការ

**លក្ខខណ្ឌកិច្ចសន្យា (អាចអនុវត្តបានចំពោះផ្នែកទី ១ និង ២)**

**១- ការស្គាល់អត្តសញ្ញាណ**

ត្រូវអានកិច្ចសន្យានេះ និងគម្រោងពេលវេលា (ដែលបង្កើតបានជាផ្នែកមួយដ៏សំខាន់នៃកិច្ចសន្យានេះ) ជាមួយគ្នាជាកិច្ចសន្យាតែមួយហើយពាក្យពេចន៍ និងការបញ្ជាក់ផ្សេងៗចំពោះអត្ថន័យជាក់លាក់ដែលបានភ្ជាប់នៅក្នុងផ្នែកណាមួយនៃ កិច្ចសន្យានេះ ឬនៃគម្រោងពេលវេលា ត្រូវមានអត្ថន័យជាក់លាក់នៅកន្លែងណាក៏ដោយដែលវាអាចកើតមាន ។

**២- ការពិពណ៌នាភាន់ច្រឡំ**

ប្រសិនបើមានការរៀបរាប់ខុសដោយបុគ្គលទទួលការធានារ៉ាប់រង ឬនរណាម្នាក់ដែលដើរតួនាទីជំនួសនៃទ្រព្យសម្បត្តិ ដែលធានា ឬអគារណាមួយ ឬកន្លែងដែលទុកដាក់ទ្រព្យសម្បត្តិនោះ ឬអាជីវកម្ម ឬបរិវេណដែលការធានារ៉ាប់រងនេះ សំដៅទៅលើ ឬការបង្ហាញខុសចំពោះការពិតដែលគេបានដឹងសម្រាប់ការវាយតម្លៃហានិភ័យ ឬការលប់

ចោលណាមួយ ដើម្បីបង្ហាញពីការពិត ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនធ្វើសំណងចំពោះទ្រព្យសម្បត្តិដែលប៉ះពាល់ដោយការ ពិពណ៌នាខុស ការបង្ហាញខុស ឬការខកខានមិនបានប្រាប់ ។

**៣- ការបញ្ឈប់ហានិភ័យ**

នៅក្នុងស្ថានភាពណាមួយខាងក្រោម ការធានារ៉ាប់រងក្រោមកិច្ចសន្យានេះ លែងមានសុពលភាពចំពោះទ្រព្យសម្បត្តិប្រសិន បើបុគ្គលទទួលការធានារ៉ាបរងមុនការកើតមានការបាត់បង់ ឬការខូចខាតមិនមានការអនុញ្ញាតយល់ព្រមពីធានាការី ដែលបញ្ជាក់យល់ព្រមលើកិច្ចសន្យានេះ ។

(ក) ប្រសិនបើពាណិជ្ជកម្ម ឬការផលិតដែលធ្វើឡើងត្រូវបានផ្លាស់ប្តូរ ឬប្រសិនបើលក្ខណៈនៃការកាន់កាប់ ឬស្ថានភាព ដទៃទៀតប៉ះពាល់ដល់អាគារ ឬមានទ្រព្យសម្បត្តិដែលត្រូវបានធានាបានផ្លាស់ប្តូរនៅក្នុងវិធីដែលកើនឡើង ហានិភ័យនៃ ការបាត់បង់ ឬការខូចខាត ។

(ខ) ប្រសិនបើអាគារដែលត្រូវបានធានា ឬមានទ្រព្យសម្បត្តិដែលត្រូវបានធានាបែជាទុកចោល ហើយនៅតែមានរយៈពេលច្រើនជាងសាមសិប (៣០) ថ្ងៃ ។

(គ) ប្រសិនបើទ្រព្យសម្បត្តិដែលត្រូវបានធានាត្រូវរុះរើទៅកាន់អាគារ ឬទីកន្លែងណាមួយក្រៅពីកន្លែងដែលត្រូវបានធានារ៉ាប់រងខាងលើដូចដែលបានបង្ហាញ ។

(ឃ) ប្រសិនបើផលប្រយោជន៍នៅក្នុងទ្រព្យសម្បត្តិ ដែលត្រូវបានធានាផ្ទេរពីបុគ្គលទទួលការធានារ៉ាប់រងដោយមរតក ឬតាម នីតិវិធីច្បាប់ ។

(ង) ប្រសិនបើមានការជូនដំណឹងអោយបោះបង់ដោយដីការបស់អាជ្ញាធរមូលដ្ឋាន សម្រាប់តម្រូវការប្រើប្រាស់ទ្រព្យ សម្បត្តិឯកជនជាបណ្តោះអាសន្ន ឬការទទួលយកដីដែលជាទ្រព្យសម្បត្តិរបស់បុគ្គលទទួលការធានារ៉ាប់រងតាំងនៅត្រូវ បានចេញប័ណ្ណកាន់កាប់ ។

(ច) យោងតាមជំពូក ២នេះ ប្រសិនបើមានការខូចខាត ឬបន្តដោយអ្នកត្រួតពិនិត្យការបិទក្រុមហ៊ុន ឬអ្នកត្រួតពិនិត្យឡើងវិញ ឬមិនត្រូវបានបន្តជាអចិន្ត្រៃយ៍ ។

**៤- ការលុបចោល**

ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ចប់នៅពេលណាមួយ តាមការស្នើសុំរបស់បុគ្គលទទួលការធានារ៉ាប់រងនៅក្នុងករណី ដែលធានាការីនឹងរក្សាអត្រារយៈពេលខ្លីសម្រាប់អតិថិជន សម្រាប់ពេលវេលាដែលកិច្ចសន្យានេះនៅជាធរមាន ។ ការធានារ៉ាប់រងនេះអាចត្រូវបានបញ្ចប់តាមជម្រើសរបស់ធានាការី ក្នុងរយៈពេលជូនដំណឹងសាមសិប (៣០) ថ្ងៃជាធរមាន ដែលបានផ្តល់អោយអ្នកទទួលបានការធានា ដែលក្នុងករណីធានាការីនឹងជឿជាក់ដើម្បីសងតាមការទាមទារនូវ សមាមាត្រតាម អត្រានៃបុព្វលាភសម្រាប់ខែដែលមិនទាន់ផុតសុពលភាពចាប់ពីកាលបរិច្ឆេទនៃការលុបចោល ។

**៥- ការការពារ និងការថែទាំ**

បុគ្គលទទួលការធានារ៉ាប់រងរាល់ពេលទាំងអស់អាចអនុវត្តនូវជំហានដ៏សមរម្យ ដើម្បីការពារទ្រព្យសម្បត្តិដែលត្រូវបាន ធានា និងថែរក្សាវាក្នុងស្ថានភាពកែលម្អដ៏សមស្រប ។ បុគ្គលទទួលការធានារ៉ាប់រងអាចចាប់ផ្តើមអនុវត្តការឃ្លាំមើលនៃ បញ្ញត្តិ ដែលទាក់ទងទាំងអស់តាមអនុសាសន៍របស់អ្នកផលិត និងបទបញ្ញត្តិផ្សេងទៀតទាក់ទងទៅនឹងការប្រើប្រាស់ ដោយសុវត្ថិភាព និងការត្រួតពិនិត្យទ្រព្យសម្បត្តិដែលត្រូវបានធានា ។

**៦- ការទាមទារ**

ប្រសិនបើព្រឹត្តិការណ៍ណាមួយកើតឡើង ឬទំនងជាកើតឡើងចំពោះការទាមទារក្រោមកិច្ចសន្យានេះតាមការ ដឹងរបស់ គាត់ បុគ្គលទទួលការធានារ៉ាប់រងត្រូវៈ

(ក) ភ្លាមៗ

(i) ចាប់ផ្តើមកាត់បន្ថយការបាត់បង់ ឬខូចខាតជាអតិបរិមា និងគ្រប់គ្រងទ្រព្យសម្បត្តិដែលបាត់បង់។

(ii) ផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ធានាការី និង

(iii) ផ្តល់ការជូនដំណឹងដល់នគរបាលក្នុងករណីមានការលួច ឬសង្ស័យថាមានការលួច ឬការខូចខាតដែលមានគំនិតព្យាបាទ និងដោយចេតនា

(ខ) ក្នុងរយៈពេលសាមសិប៣០ថ្ងៃ ឬពេលវេលាបន្ថែមលើនេះដែលបុគ្គលទទួលការធានារ៉ាប់រងអាចអនុញ្ញាតិលើ ការ បញ្ជូនជាលាយលក្ខណ៍អក្សរទៅកាន់បុគ្គលទទួលការធានារ៉ាបង់រង

(i) ការទាមទារជាលាយលក្ខណ៍អក្សរសម្រាប់ការបាត់បង់ ឬការខូចខាតដែលគណនីមានលក្ខណៈពិសេស ដែល អាចអនុវត្តដោយសមហេតុផលសម្រាប់របស់របរជាច្រើន ឬសម្ភារៈទ្រព្យសម្បត្តិដែលបាត់បង់ និងខូចខាត និងចំនួនទឹកប្រាក់នៃការបាត់បង់ និងខូចខាតតាមតម្លៃនីមួយៗ ក្នុងពេលបាត់បង់ និងខូចខាត ។

(ii) លក្ខណៈពិសេសនៃការធានារ៉ាប់រងដទៃផ្សេងទៀតបើមានបុគ្គលទទួលការធានារ៉ាប់រងនៅគ្រប់ពេល ទាំង អស់ មានការចំណាយ ផលិត លទ្ធកម្ម និងផ្តល់ដល់ធានាការីនូវគម្រោងជាក់លាក់បន្តទៀត ការបញ្ជាក់ សៀវភៅ ខិតប័ណ្ណ វិក្កយបត្រ ច្បាប់ចម្លង ឬសំណៅ សំណុំឯកសារតឹកតាង និងពត៌មាន ដែលទាក់ទងទៅនឹងការទាមទារ និងប្រភព និងមូលហេតុនៃការបាត់បង់ និងការខូចខាត និងស្ថានភាពដែលកើតមានការបាត់បង់ ឬការខូចខាត និងបញ្ហាដែលជាប់បំណុល ឬចំនួនបំណុលនៃធានាការីដែលអាចតម្រូវឲ្យ ដោយសមហេតុផលដោយ ឬជំនួសឲ្យធានាការីជាមួយគ្នា និងការអះអាងដោយសម្បថ ឬតាមទម្រង់ ច្បាប់ផ្សេងទៀតដែលត្រឹមត្រូវតាមការអះអាង និងបញ្ហាដែលជាប់ទាក់ទង ។

## ៧- សិទ្ធិរបស់ធានាការីបន្ទាប់ពីមានការបាត់បង់

នៅពេលដែលមានការបាត់បង់ ឬការខូចខាតលើផ្នែកណាមួយនៃទ្រព្យសម្បត្តិ ដែលត្រូវបានធានាដោយកិច្ចសន្យានេះធានាការីអាចៈ

(ក) ចុះ និងកាន់កាប់ និងថែរក្សាកម្មសិទ្ធិនៃអគារ ឬបរិវេណដែលកើតមានការបាត់បង់ ឬការខូចខាត

(ខ) កាន់កាប់ ឬតម្រូវឲ្យមានការបញ្ជូននូវទ្រព្យសម្បត្តិណាមួយ នៃបុគ្គលទទួលការធានារ៉ាប់រងក្នុងអាគារ ឬក្នុងបរិវេណនៅពេលមានការបាត់បង់ ឬខូចខាត

(គ) រក្សាទុកកម្មសិទ្ធិនៃទ្រព្យសម្បត្តិណាមួយ និងពិនិត្យប្រភេទនៃការរៀបចំផ្លាស់ប្តូរ ឬបើមិនដូច្នោះទេដោះស្រាយជាមួយនិងករណីដូចគ្នា

(ឃ) លក់ទ្រព្យសម្បត្តិណាមួយឬបោះបង់ចោលគណនីដូចគ្នារបស់អ្នកដែលពាក់ព័ន្ធ។

អំណាចដែលបានផ្ទេរតាមលក្ខខណ្ឌ នេះនឹងត្រូវបានអនុវត្តដោយធានាការី នៅគ្រប់ពេលរហូតដល់មានការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឲ្យបុគ្គលទទួលការធានារ៉ាប់រង ថាគាត់មិនធ្វើការទាមទារតាមកិច្ចសន្យានេះ ឬប្រសិនបើការទាមទារណាមួយត្រូវបានធ្វើឡើង រហូតដល់ការទាមទារនោះត្រូវបានសម្រេចចុងក្រោយ ឬ ដកយកហើយបុគ្គលទទួលការធានារ៉ាប់រង នឹងមិនត្រូវបានធ្វើដោយទង្វើណាមួយនៅក្នុងការអនុវត្ត ការអនុវត្តទាមទារដោយមិនមានភស្តុតាងនៃអំណាច ដែលមានចំពោះបំណុលសម្រាប់បុគ្គលទទួលការធានារ៉ាប់រង ឬលុបចោលសិទ្ធិដើម្បី ផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យានេះឆ្លើយតបតាមការទាមទារ ។

ប្រសិនបើអ្នកទទួលការធានា ឬបុគ្គលណាម្នាក់ដែលដើរតួនាទីជំនួសមិនអនុវត្តតាមលក្ខខណ្ឌតម្រូវរបស់ ធានាការី ឬត្រូវរាំងស្ទះ ឬរាំងធានាការីក្នុងការអនុវត្តអំណាចរបស់ខ្លួននេះ រាល់ផលប្រយោជន៍ទាំងអស់នៅក្នុងកិច្ចសន្យានេះត្រូវបានរឹបអូស ។

បុគ្គលទទួលការធានារ៉ាប់រងមិនមានសិទ្ធិក្នុងករណីណាមួយ ដើម្បីបោះបង់ចោលទ្រព្យសម្បត្តិណាមួយដល់ធានាការីថាតើកាន់កាប់កម្មសិទ្ធិរបស់ធានាការី ឬយ៉ាងណាដែរ ។

## ៨. ការដកសិទ្ធិ

ប្រសិនបើមានការទាមទារសំណងលើកិច្ចសន្យាធានារ៉ាប់រងនេះដោយមានការក្លែងបន្លំ ឬដោយមធ្យោបាយក្លែងបន្លំណាមួយ ឬឧបករណ៍ត្រូវបានប្រើប្រាស់ដោយបុគ្គលដែលត្រូវបានធានារ៉ាប់រង ឬនណាម្នាក់ប្រព្រឹត្តិក្នុងនាមខ្លួនដើម្បីទទួលបាននូវផលប្រយោជន៍ណាមួយក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ ឬប្រសិនបើការបាត់បង់ ការបំផ្លាញ ការខូចខាតត្រូវបានបង្ករដោយសកម្មភាពដោយចេតនា ឬដោយមានការផ្សំគំនិតពីបុគ្គលដែលត្រូវបានធានារ៉ាប់រងនោះផលប្រយោជន៍ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបាត់បង់។

ប្រសិនបើការទាមទារសំណងត្រូវបានធ្វើឡើង និងបដិសេធ ហើយសកម្មភាព ឬបណ្តឹងដែលមិនបានចាប់ផ្តើមក្នុងរយះពេលបី (៣) ខែបន្ទាប់ពីការបដិសេធនេះ ឬ(ក្នុងករណីមានមជ្ឈត្តកម្មទាក់ទងទៅនឹតលក្ខណ៍១៤នៃកិច្ចសន្យានេះ) ក្នុងរយះពេលបី(៣) ខែបន្ទាប់ពីមជ្ឈត្តករ ឬអាជ្ញាកណ្តាលបន្ថែមបានធ្វើសេចក្តីសម្រេចឲ្យឈ្នះ ផលប្រយោជន៍ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវបាត់បង់។

## ៩. ការកំណត់ពេលវេលា

ក្នុងករណីណាក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬការខូចខាតណាមួយបន្ទាប់ពីការអស់សុពលភាពរយះពេល ១២ ខែ

(i) ទាក់ទងនឹងផ្នែកទី ១ ចាប់ពីការកើតឡើងនៃការបាត់បង់ ឬការខូចខាត

(ii) ទាក់ទងនឹងផ្នែកទី ២ ចាប់ពីពេលបញ្ចប់នៃរយះពេលការធ្វើសំណង ឬ ប្រសិនបើក្រោយមក ៣ខែបន្ទាប់ពីកាលបរិច្ឆេទដែលការធ្វើសំណងនឹងត្រូវបានធ្វើឡើង ឬការទទួលខុសត្រូវត្រូវបានទទួលដោយក្រុមហ៊ុនធានារ៉ាប់រងធ្វើសំណងលើការខូចខាតដែលបណ្តាលឲ្យមានការទាមទារសំណងដូចដែលបានរៀបរាប់ខាងលើ

ប្រសិនបើការទាមទារសំណងមិនមែនជាប្រធានបទនៃបណ្តឹង ឬមជ្ឈត្តកម្មនោះទេ។

## ១០. ឧបាទេសកម្ម(សិទ្ធិជំនួស)

បុគ្គលដែលត្រូវបានធានារ៉ាប់រង ដោយការចំណាយរបស់ក្រុមហ៊ុនធានារ៉ាប់រង នឹងធ្វើ និងយល់ព្រមក្នុងការធ្វើ និងអនុញ្ញាតឲ្យធ្វើនូវសកម្មភាពទាំងអស់នេះ និងអ្វីៗដែលអាចចាំបាច់ ឬមានតម្រូវការដោយសមហេតុផលដោយបុគ្គលដែលត្រូវបានធានារ៉ាប់រងសម្រាប់គោលបំណងដាក់ឲ្យអនុវត្តនូវសិទ្ធិ និងមធ្យោបានដោះស្រាយណាមួយ ឬសម្រាប់គោលបំណងទទួលបាននូវសំណងពីភាគីដទៃទៀតដែលក្រុមហ៊ុនធានារ៉ាប់រងនឹង ឬអាចនឹងមានសិទ្ធិទទួលបាន ឬមានសិទ្ធិជំនួសលើកការចេញថ្លៃការបាត់បង់ ការបំផ្លាញ ឬការខូចខាតក្រោមកិច្ចសន្យាធានារ៉ាប់រងនេះថាតើសកម្មភាពនេះ និងអ្វីៗផ្សេងទៀតនឹងចាំបាច់ ឬមានតម្រូវការមុនពេល ឬក្រោយពេលការធ្វើសំណងនេះដោយក្រុមហ៊ុនធានារ៉ាប់រង។

## ១១. ការធ្វើវិភាគទាន

នៅពេលមានការខាតបង់ ឬការខូចខាតកើតឡើងចំពោះទ្រព្យសម្បត្តិធានា ទោះជាធ្វើឡើងដោយលោកអ្នក ឬអ្នកដទៃណាមួយ ឬក្រុមណាក៍ដោយ ប្រសិនបើមានការធានារ៉ាប់រងណាមួយ ឬការធានារ៉ាប់រងទាំងឡាយណាផ្សេងទៀតដែលមានសុពលភាពចំពោះទ្រព្យសម្បត្តិដូចគ្នា យើងមិនត្រូវទទួលខុសត្រូវលើការទូទាត់សំណង ឬវិភាគទានច្រើនជាងសមាមាត្រតាមអត្រានៃការខាតបង់ ឬការខូចខាតនោះទេ។

## ១២. មធ្យមភាគ

ទឹកប្រាក់ធានារ៉ាប់រងសរុបនៃចំនុចនិមួយៗក្រោមផ្នែកទី១ និងទី២នៃកិច្ចសន្យានេះត្រូវបានប្រកាសឲ្យអនុវត្តតាមមធ្យមភាគដាច់ដោយឡែកៗពីគ្នា។

ផ្នែកទី១:

ប្រសិនបើ ទ្រព្យសម្បត្តិធានានៅពេលមានការបាត់បង់ ការបំផ្លាញ ឬការខូចខាតដែលសរុបមានតម្លៃលើសទឹកប្រាក់ធានារ៉ាប់រងសរុប នោះបុគ្គលដែលត្រូវបានធានារ៉ាប់រងនឹងត្រូវចាត់ទុកថាលោកអ្នកជាអ្នកធានារ៉ាប់រងផ្ទាល់ចំពោះចំនួនខុសគ្នានេះ ហើយលោកអ្នកត្រូវទទួលរ៉ាប់រងតាមអត្រាសមាមាត្រនៃការខាតបង់នេះ។ រាល់កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រងនេះ ប្រសិនបើច្រើនជាងមួយត្រូវអនុវត្តតាមលក្ខខណ្ឌនេះដោយឡែកៗពីគ្នា។

ផ្នែកទី២:

ការធានារ៉ាប់រងត្រូវបានកំណត់ចំពោះការចំណេញសរុប ដោយសារការកាត់បន្ថយចំណូលអាជីវកម្ម និងការកើនឡើងតម្លៃធ្វើការ និងចំនួនទឹកប្រាក់ដែលត្រូវបង់ជាការធ្វើសំណងដូចខាងក្រោម:

ក) ទាក់ទងនឹងការកាត់បន្ថយចំណូលអាជីវកម្ម:ចំនួនទឹកប្រាក់ដែលបង្កើតដោយការអនុវត្តចំពោះការចំណេញសរុបទៅលើចំនួនដែលចំណូលអាជីវកម្មក្នុងអំឡុងរយៈពេលធ្វើសំណងជាលទ្ធផលនៃការខូចខាតមិនដល់ចំណូលអាជីវកម្មតាមបទដ្ឋាន។

ខ) ទាក់ទងនឹងការកើនឡើងតម្លៃការងារ: ការចំណាយបន្ថែម (ដោយអនុវត្តតាមលក្ខខណ្ឌនៃ ខកម្រៃទូទៅដែលមិនមានធានា) ដែលត្រូវចេញថ្លៃជាចាំបាច់ និងដោយសមហេតុផលសម្រាប់គោលបំណងតែមួយគត់ក្នុងការជៀសវាង ឬបន្ថយការថយចុះចំណូលអាជីវកម្ម ដែលប៉ុន្តែសម្រាប់ការចំណាយនោះអាចនឹងមានឡើងក្នុងអំឡុងរយៈពេលធ្វើសំណងជាលទ្ធផលនៃចំនួនការកាត់បន្ថយដែលត្រូវជៀសវាង:

ដកចំនួនទឹកប្រាក់ណាមួយដែលសន្សំក្នុងអំឡុងរយៈពេលធ្វើសំណងទាក់ទិននឹងកម្រៃ និងការចំណាយផ្សេងៗនៃអាជីវកម្មដែលចំណាយចេញពីប្រាក់ចំណេញសរុប ដែលអាចត្រូវបញ្ឈប់ ឬត្រូវកាត់បន្ថយជាលទ្ធផលនៃការខូចខាត:

ដរាបណា ប្រសិនបើចំនួនទឹកប្រាក់ធានាសរុបដោយកម្មវត្ថុនេះតិចជាងចំនួនទឹកប្រាក់ដែលបង្កើតដោយការអនុវត្តអត្រានៃប្រាក់ចំណេញសរុបចំពោះចំណូលអាជីវកម្មប្រចាំឆ្នាំ ( ឬចំពោះការកើនឡើងជាច្រើនតាមសមាមាត្រដែលរយៈពេលការធ្វើសំណងអតិបរមាលើសពីដប់ពីខែ) ចំនួនទឹកប្រាក់ដែលត្រូវបង់នឹងត្រូវកាត់បន្ថយជាសមាមាត្រ។

## ១៣. កម្រិតមិនធ្វើសំណង

កិច្ចសន្យាធានារ៉ាប់រងនេះមិនធានាចំពោះកម្រិតមិនធ្វើសំណងដែលបានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងចំពោះការខូចខាតនីមួយៗដែលបានបញ្ជាក់បន្ទាប់ពីបានអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងដោយរួមបញ្ចូលទាំងលក្ខខណ្ឌសមាមាត្រផ្សេងៗ។

នេះត្រូវបានធានាបន្ថែមថាក្នុងអំឡុងពេលមានសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រង លោកអ្នកនឹងមិនមានការធានារ៉ាប់រងចំពោះកម្រិតមិនធ្វើសំណងដែលមានចែងក្នុងតារាងឧបសម្ព័ន្ធ។

## ១៤. មជ្ឈត្តកម្ម

ប្រសិនបើមានការខ្វែងគំនិតគ្នាទាក់ទងនឹងចំនួនទឹកប្រាក់នៃការបាត់បង់ ឬការខូចខាតនោះ ការខ្វែងគំនិតនេះនឹងត្រូវបញ្ជូនឲ្យមានការសម្រេចពីអាជ្ញាកណ្តាលដែលតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីដែលមានវិវាទ ឬប្រសិនបើភាគីទាំងពីមិនអាចឯកភាពគ្នាលើមជ្ឈត្តករតែមួយចំពោះសេចក្តីសម្រេចនៃមនុស្សជាសត្យានុម័តពីនាក់ដែលមជ្ឈត្តករនៃមនុស្សទាំងនោះនឹងត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីណាមួយក្នុងរយៈពេលពី (២) ខែប្រតិទិន បន្ទាប់ពីត្រូវបានទាមទារឲ្យធ្វើដូច្នេះជាលាយលក្ខណ៍អក្សរដោយភាគីដទៃទៀត។ ក្នុងករណីភាគីណាមួយបដិសេធ មិនបានតែងតាំងមជ្ឈត្តករក្នុងរយៈពេលពី (២) ខែប្រតិទិនបន្ទាប់ពីទទួលការជូនតំណឹងជាលាយលក្ខណ៍អក្សរដែលតម្រូវឲ្យមានការតែងតាំងដែលភាគីដទៃទៀតមានសិទ្ធិក្នុងការតែងតាំងមជ្ឈត្តករតែមួយ និងក្នុងករណីមានការមិនចុះសម្រុងគ្នារវាងមជ្ឈត្តករ នឹងត្រូវបញ្ចូលទៅឲ្យមានការសម្រេចពីមជ្ឈត្តករបន្ថែមដែលនឹងត្រូវតែងតាំងដោយពួកគេជាលាយលក្ខណ៍អក្សរមុនពេលចាប់ផ្តើមធ្វើការត្រួតពិនិត្រ និងដែលនឹងអង្គុយជាមួយមជ្ឈត្តករ ហើយនឹងធ្វើជាអធិបតីនៅឯអង្គប្រជុំ។ មរណៈភាពរបស់ភាគីណាមួយនឹងមិនដកហូត ឬប៉ះពាល់ដល់សិទ្ធិអំណាចរបស់មជ្ឈត្តករ ឬមជ្ឈត្តករបន្ថែមឡើយ ហើយក្នុងករណីមជ្ឈត្តករ ឬមជ្ឈត្តករបន្ថែមទទួលមរណៈភាព មជ្ឈត្តករ ឬមជ្ឈត្តករបន្ថែមផ្សេងទៀតនឹងត្រូវតែងតាំងជំនួសដោយភាគីមានវិវាទ ឬមជ្ឈត្តករ (អាស្រ័យទៅតាមកាលៈទេសៈ)។ ការចេញថ្លៃវិនិច្ឆ័យ និងសេចក្តីសម្រេចនឹងត្រូវសម្រេចដោយមជ្ឈត្តករ ឬមជ្ឈត្តករបន្ថែមដែលធ្វើសេចក្តីសម្រេច។ នេះត្រូវបានចែង និងប្រកាសជាចំហរថា នេះជាលក្ខខណ្ឌមុនមានសិទ្ធិនៃសកម្មភាព ឬបណ្តឹងណាមួយលើកិច្ចសន្យាធានារ៉ាប់រងនេះដែលថាសេចក្តីសម្រេចដោយមជ្ឈត្តករ ឬមជ្ឈត្តករបន្ថែមនៃចំនួនការបាត់បង់ ឬការខូចខាត ប្រសិនបើមានវិវាទនឹងត្រូវទទួលបានជាមុនសិន។

## ១៥. ការជួសជុល និងការផ្លស់ប្តូរ

ក្រុមហ៊ុនធានារ៉ាប់រងអាចមានជម្រើសដោយធ្វើការជួសជុលឲ្យដូចដើមវិញ ផ្លាស់ប្តូរទ្រព្យសម្បត្តិដែលខូចខាត ឬផ្នែកណាមួយនៃទ្រព្យសម្បត្តិនោះជំនួសឲ្យការធ្វើសំណងជាទឹកប្រាក់សម្រាប់ការខូចខាត ឬការបាត់បង់នេះ ឬអាចចូលរួមជាមួយក្រុមហ៊ុន ឬក្រុមហ៊ុនធានារ៉ាប់រងដទៃទៀតក្នុងការធ្វើដូច្នេះ ប៉ុន្តែយើងមិនមានកាតព្វកិច្ចចំពោះការជួសជុលឲ្យដូចដើមវិញទាំងស្រុងនោះទេ ប៉ុន្តែប្រសិនបើមានកាលៈទេសៈអនុញ្ញាត និងលក្ខខណ្ឌគ្រប់គ្រាន់ ហើយក្នុងករណីណាក៏ដោយយើងមិនមានកាតព្វកិច្ចពង្រីកការជួសជុលឲ្យដូចដើមវិញបន្ថែមឲ្យលើសថ្លៃចំណាយសម្រាប់ការជួសជុលទ្រព្យសម្បត្តិឡើងវិញ និងមិនលើសទឹកប្រាក់ធានារ៉ាប់រងនៅពេលដែលមានការខូចខាត ឬខាតបង់។

ប្រសិនបើយើងជ្រើសរើសយកការជួសជុលឲ្យដូចដើមវិញ ឬការផ្លាស់ប្តូរទ្រព្យសម្បត្តិណាមួយ លោកអ្នកត្រូវផ្តល់ជូនយើងដោយចំណាយខ្លួនឯងនូវ ប្លង់ សេចក្តីបញ្ជាក់លម្អិត វង្វាស់ខ្នាត បរិមាណ និងចំនុចពិសេសផ្សេងៗទៀត ដែលយើងត្រូវការ ហើយសកម្មភាពដែលធ្វើ ឬជម្រុញឲ្យធ្វើដោយយើង ទាក់ទងនឹងការជួសជុលឲ្យដូចដើមវិញ មិនត្រូវចាត់ទុកថាយើងជ្រើសរើសយកជម្រើសនេះទេ។

**១៦. ការចំណាយលើការពន្លត់អគ្គិភ័យ និងក្រុមសង្គ្រោះ**

ការធានារ៉ាប់រងនៃកិច្ចសន្យាធានារ៉ាប់រងនេះពង្រីកបន្ថែមការធានាលើ៖

i) ប្រាក់ឈ្នួលរបស់និយោជិតរបស់លោកអ្នកក្រៅពីសមាជិកកងពន្លត់អគ្គិភ័យដែលធ្វើការពេញម៉ោង។

ii) ថ្លៃចំណាយសម្រាប់ការផ្លាស់ប្តូរឧបករណ៍ពន្លត់អគ្គិភ័យ និងការបំផ្លាញ ឬការខូចខាតសម្ភារ(រួមមានសំលៀកបំពាក់និយោជិក និងសម្ភារផ្ទាល់ខ្លួន ប្រសិនបើមិនមានធានាជាពិសេស)

iii) ថ្លៃចំណាយផ្សេងៗ(រួមមានការបាត់បង់ ឬការខូចខាតចំពោះទ្រព្យសម្បត្តិដើម្បីយកផ្លូវចូលពន្លត់អគ្គិភ័យ)

ដែលត្រូវបានចំណាយជាចាំបាច់ និងសមហេតុផលក្នុងការពន្លត់អគ្គិភ័យ ឬក្នុងការស្រោចស្រង់ទ្រព្យសម្បត្តិ ឬជីវិតពីការបាត់បង់ ឬការខូចខាតដោយហានិភ័យនៅក្នុងកិច្ចសន្យានេះ នៅឯ ឬនៅជាប់នឹងទីតាំងទ្រព្យសម្បត្តិដែលធានា ឬភ្លាមៗគម្រាមកំហែងដល់ទ្រព្យសម្បត្តិនោះ។

**ការធានាបុព្វលាភ**

វាគឺជាលក្ខខណ្ឌមូលដ្ឋាន និងពិសេសបំផុតនៃកិច្ចសន្យាធានារ៉ាប់រងដែលការផុតកំណត់បុព្វលាភ នឹងត្រូវបង់ និងទទួលដោយក្រុមហ៊ុនក្នុងរយៈពេលសាមសិប (៣០)ថ្ងៃចាប់ពីកាលបរិច្ឆេទចាប់ផ្តើមនៃកិច្ចសន្យា/ការអនុម័ត/លិខិតបន្ត។ ប្រសិនបើលក្ខខណ្ឌនេះមិនស្របទេនោះ កិច្ចសន្យានេះត្រូវបានលប់ចោលដោយស្វ័យប្រវត្តិ ហើយ ក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភក្នុងសមាមាត្រថេរក្នុងរយៈពេលដែលពួកគេជួបហានិភ័យ ។
នៅកន្លែងដែលបុព្វលាភត្រូវបង់យោងតាមលិខិតធានានេះត្រូវបានទទួលដោយភ្នាក់ងារដែលផ្តល់ សិទ្ធិរបស់ក្រុមហ៊ុនការបង់ប្រាក់នឹងត្រូវបានទទួលដោយក្រុមហ៊ុនសម្រាប់គោលបំណងនៃលិខិតធានានេះ និងបន្ទុកលើ បុព្វលាភដែលត្រូវបង់ ត្រូវបានទទួលដោយបុគ្គលណាម្នាក់រួមបញ្ចូលទាំងភ្នាក់ងារធានារ៉ាប់រងដែលមិនបានផ្តល់សិទ្ធិ អនុញ្ញាតិអោយទទួលនូវបុព្វលាភនេះផ្អែកលើក្រុមហ៊ុន ។

កម្មវត្ថុនៃខ និងលក្ខខណ្ឌនៃកិច្ចសន្យានេះ ។

**ខ បញ្ជាក់អះអាងផ្អែកពត៌មានវិទ្យា**

ការខូចខាតទ្រព្យសម្បត្តិដែលគ្របដណ្តប់លើការធានារ៉ាប់រងនេះ នឹងមានន័យថាជាការខូចខាតផ្នែករូបវន្តចំពោះ លក្ខណៈនៃទ្រព្យសម្បត្តិ ។
ការខូចខាតផ្នែករូបវន្តចំពោះលក្ខណៈនៃទ្រព្យសម្បត្តិ នឹងមិនត្រូវរួមបញ្ចូលការខូចខាតទិន្នន័យ ឬ software ជា ពិសេសការផ្លាស់ប្តូរដែលប៉ះពាល់ដល់ទិន្នន័យ software ឬកម្មវិធីកុំព្យូទ័រ ដែលកើតមានដោយសារការលុប ការផ្លាស់ប្តូរដោយចៃដន្យ ឬទ្រង់ទ្រាយខុសពីរចនាសម្ព័ន្ធដើម ។
ជាលទ្ធផល ការធានារ៉ាប់រងនេះមិនរួមបញ្ចូលនូវចំនុចខាងក្រោម:

(ក) ការបាត់បង ឬការខូចខាតទិន្នន័យ ឬ software ជាពិសេសការផ្លាស់ប្តូរដែលប៉ះពាល់ដល់ទិន្នន័យ software ឬកម្មវិធីកុំព្យូទ័រ ដែលកើតមានដោយសារការលុប ការផ្លាស់ប្តូរដោយចៃដន្យ ឬទ្រង់ទ្រាយខុសពីរចនា សម្ព័ន្ធដើម និង

ការបាត់បង់ដោយការផ្អាកអាជីវកម្មណាមួយបណ្តាលមកពីការបាត់បង់ និងការខូចខាតបែបនេះ ។ ទោះបីជាថាមិនរួមបញ្ចូលចំនុចនេះ ការបាត់បង ឬការខូចខាតទិន្នន័យ ឬ software ដែលជាលទ្ធផលផ្ទាល់នៃការ ខូចខាតផ្នែករូបវ័ន្ត ដែលត្រូវបានធានាចំពោះ លក្ខណៈនៃទ្រព្យសម្បត្តិដែលត្រូវបានគ្របដណ្តប់ ។

(ខ) ការបាត់បង់ ឬការខូចខាតដោយសារភាពមិនប្រក្រតីនៃតួនាទី លទ្ធភាពដែលអាចមាន ទំហំនៃការប្រើប្រាស់ ឬលទ្ធភាពទទួលបានទិន្នន័យ software ឬកម្មវិធីកុំព្យូទ័រ និងការបាត់បង់ដោយការផ្អាកអាជីវកម្ម បណ្តាល មកពីការបាត់បង់ ឬខូចខាតទិន្នន័យនេះ ។

**ការអនុម័តដោយមិនរួមបញ្ចូលអំពើភេរវកម្ម**

ទោះបីជាថាបញ្ញត្តិណាមួយដែលផ្ទុយទៅនឹងការធានារ៉ាប់រងនេះ ឬការអនុម័តណាមួយក្នុងនេះដែលបានព្រមព្រៀង ថាការធានារ៉ាប់រងនេះមិនរួមបញ្ចូលការបាត់បង់ ការខូចខាត តម្លៃ ឬចំណាយនៃលក្ខណៈណាមួយដោយផ្ទាល់ ឬដោយប្រយោល ឬដែលប្រយោលដែលបង្កឡើងដោយ ឬមកពី ឬទាក់ទងជាមួយសកម្មភាពភេរវកម្មណាមួយដោយមិនគិតពីមូលហេតុដ៏ទៃទៀត ឬព្រឹត្តិការណ៍ដែលរួមចំណែកនៅពេលថ្មីៗ ឬលទ្ធផលណាមួយផ្សេងទៀតចំពោះការបាត់បង់ ។
សម្រាប់គោលបំណងនៃការអនុម័តនេះសកម្មភាពភេរវកម្មមានន័យថាសកម្មភាពដែលរួមបញ្ចូលដោយមិនកំណត់ ការប្រើប្រាស់កម្លាំង ឬអំពើហឹង្សា និង/ឬការគំរាមគំហែង នៃបុគ្គលណាម្នាក់ ឬជាក្រុមថាតើធ្វើសកម្មភាព តែឯង ឬជំនួសអោយ ឬមានទំនាក់ទំនងជាមួយអង្គការណាមួយ ឬរដ្ឋាភិបាលដែលធ្វើឡើងសម្រាប់គោលបំណងនយោបាយសាសនាមនោគមន៍វិជ្ជា ឬគោលបំណងប្រហាក់ប្រហែល ដោយរួមទាំងការប៉ុនប៉ងធ្វើអោយមាន ឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬធ្វើអោយសាធារណៈជន ឬផ្នែកសាធារណៈណាមួយ ស្ថិតក្នុងការភ័យខ្លាច។ ការអនុម័តនេះមិនរួមបញ្ចូលការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយក្នុងលក្ខណៈណាមួយដោយផ្ទាល់ ឬ ដោយប្រយោលដែលបង្កឡើងដោយ ឬមកពី ឬទាក់ទងជាមួយសកម្មភាពណាមួយដែលធ្វើឡើងដើម្បីត្រួតត្រា ការពារ បង្ក្រាប ឬក្នុងមធ្យោបាយណាមួយដែលទាក់ទងនឹងសកម្មភាពភេរវកម្ម ។
ប្រសិនបើក្រុមហ៊ុនចោទប្រកាន់ថា ដោយហេតុផលណាមួយចំពោះការមិនរួមបញ្ចូលនេះ ការបាត់បង់ ការខូចខាត ឬការចំណាយ មិនត្រូវបានគ្របដណ្តប់ដោយការធានារ៉ាប់រងនេះ ការបញ្ជាក់អំពីការផ្តល់អោយផ្ទុយពីនេះជាបន្ទុករបស់បុគ្គលទទួលការធានារ៉ាប់រង ។
ក្នុងករណីផ្នែកណាមួយនៃការអនុម័តនេះត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន ផ្នែកដែលនៅសល់ត្រូវស្ថិតនៅជាធរមានពេញលេញ ។

NMA 2921

ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០១

**ខចែងស្តីអំពីការដាក់កំហិតទណ្ឌកម្មនិងករណីលើកលែង (LMA 3100)**

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្តល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្តល់ប្រាក់សំណងណាមួយ ឬផ្តល់អត្ថប្រយោជន៍ណាមួយ ដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះបានឡើយ ដែលការផ្តល់សំណងឬអត្ថប្រយោជន៍ទាំងនោះធ្វើឲ្យក្រុមហ៊ុនធានារ៉ាប់រង ប្រឈមមុខនឹងការដាក់ទណ្ឌកម្មណាមួយ ការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្មច្បាប់ ឬនិយតកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។